ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខ័ណ្ឌកម្មវិធីសិក្សា

## ថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ

## ជំនាញ

## គោលនយោបាយអប់រំ និងភាពជាអ្នក ដឹកនាំក្នុងវិស័យអប់រំ

វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២០

# បុព្វកថា

ការកសាងសមត្ថភាព និងការអភិវឌ្ឍមូលធនមនុស្សឱ្យមានគុណភាព ភាពឆ្លើយតប និងសីលធម៌រស់នៅល្អ គឺជាអាទិភាពទី១ និងជាគោលដៅគន្លឹះ ដែលរាជរដ្ឋាភិបាលនីតិកាលទី៦ បាននិងកំពុងអនុវត្ត តាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។

ដើម្បីរួមចំណែកក្នុងការសម្រេចឱ្យបានយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ និងបានដាក់ចេញនូវគោលនយោបាយអប់រំ ដោយផ្តោតជាចម្បងទៅលើការធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងបានដាក់ចេញនូវកម្មវិធីកំណែទម្រង់ចំនួន១៥ចំណុច ដោយឈរលើសសរស្តម្ភចំនួន០៥។

ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការការងារនៅក្នុងប្រទេស តំបន់ និងសកលលោក តាមរយៈការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈអ្នកសិក្សា ទាំងផ្នែកចំណេះដឹង និងជំនាញថ្មីៗ ក្នុងការបំពេញតួនាទីជាមន្ត្រីរដ្ឋបាលអប់រំ អ្នករៀបចំគោលនយោបាយអប់រំ អ្នករៀបចំផែនការអប់រំ អ្នកដឹកនាំ និង គ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ប្រកបដោយមនសិការវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងមានប្រសិទ្ធភាព ក្នុងការចូលរួមផ្តល់សេវាអប់រំឱ្យស្របតាមបរិបទនៃការអប់រំសតវត្សរ៍ទី២១ ក្នុងការអភិវឌ្ឍសង្គមពុទ្ធិ និងវិបុលភាព។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងមានជំនឿយ៉ាងមុតមាំថា ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាញគោលនយោបាយអប់រំ និងជំនាញភាពជាអ្នកដឹកនាំ ក្នុងវិស័យអប់រំនេះ នឹងជួយលើកកម្ពស់សមត្ថភាពអ្នកសិក្សា ឱ្យបានយល់ដឹងកាន់តែច្បាស់ថែមទៀត ពីច្បាប់ គោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងមានវិជ្ជាជីវៈរឹងមាំក្នុងការដឹកនាំ និងគ្រប់គ្រង នូវរាល់ដំណើរការប្រចាំថ្ងៃរបស់សាលារៀន គ្រឹះស្ថាន និងអង្គភាពរបស់ខ្លួន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះស្នាដៃដ៏ល្អ របស់ក្រុមការងារដែលបានខិតខំអភិវឌ្ឍក្របខ័ណ្ឌកម្មវិធីសិក្សានេះឡើង។

ថ្ងៃសុក្រ ៣កើត ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## I. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តម | យក់ ង៉ុយ | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៤. ឯកឧត្តម | ម៉ក់ ងយ | អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា |
| ៥. លោកជំទាវ | យួន វិច្ឆិកា | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ |

## II. គណៈកម្មការរៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ |
| ២. លោកបណ្ឌិត | នូវ វ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៣. លោកបណ្ឌិត | ហុង គឹមជាង | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ |
| ៤. លោកបណ្ឌិត | សុខ សូត្រ | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃស.ភ.ភ.ព |
| ៥. លោកបណ្ឌិត | ឈួក ច័ន្ទឆាយា | អនុប្រធាននា.បណ្ដុះបណ្ដាលនិងវិក្រឹតការ |
| ៦. លោកបណ្ឌិត | វ័ន្ន ឆាង | អគ្គលេខាធិការរងនៃគ.ទ.ក |
| ៧. ឯកឧត្តម | ទេព ភិយ្យោរិទ្ធ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ៨. លោកបណ្ឌិត | ហ៊ាត់ ប៊ុនហេ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ |
| ៩. លោកបណ្ឌិត | ហេង គ្រេង | ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ |
| ១០. លោកបណ្ឌិត | ម៉ម សុជាតិ | សាស្ត្រាចារ្យស.ភ.ភ.ព |
| ១១. លោក | ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ |
| ១២. លោក | ចាប រតនា | អនុប្រ.ដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ |
| ១៣. លោកបណ្ឌិត | ឈាង សង្ឃាត | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៤. លោកបណ្ឌិត | អាន រ៉ូប្រាវ | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៥. កញ្ញា | ហ៊ សុីវី | ប្រធានការិ.នៃវិ.បច្ចេកវិទ្យាកំពង់ស្ពឺ |
| ១៦. កញ្ញា | ជិត ចាន់វន្នី | អនុប្រធានលេខាធិការដ្ឋាននៃអគ្គ.អប់រំ |
| ១៧. លោក | ម៉ែន សំណាង | មន្ត្រីលេខាធិការដ្ឋាននៃអគ្គ.អប់រំ |

## III. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោក | លឹម វ៉ាន់ | អនុប្រ.ដេប៉ាតឺម៉ង់ វដអ |
| ២. លោក | លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ វដអ |
| ៣. លោកស្រី | សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ វដអ |
| ៤. លោក | ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ វដអ |
| ៥. លោក | ម៉ែន សុខសុន្នី | មន្ត្រីដេប៉ាតឺម៉ង់ វដអ |

# មាតិកា

**បុព្វកថា** ....................................................................................................i
**គណៈកម្មការ** ...............................................................................................ii
**ជំពូកទី១៖ ព័ត៌មានទូទៅ** .......................................................................1
១. សេចក្តីផ្តើម ........................................................................................ 1
២. ឈ្មោះកម្មវិធីសិក្សា ............................................................................ 1
៣. ចក្ខុវិស័យ .......................................................................................... 2
៤. គោលបំណង ....................................................................................... 2
៥. លទ្ធផលសិក្សាដែលរំពឹងទុក .............................................................. 2
៦. សមត្ថភាពវិជ្ជាជីវៈដែលរំពឹងទុក .......................................................... 3
៧. អាជីពដែលរំពឹងទុក ............................................................................. 3
**ជំពូកទី២៖ សេចក្តីលម្អិតកម្មវិធីសិក្សា** ................................................... 4
១. ប្រភេទកម្មវិធីសិក្សា និងចំនួនក្រេឌីត ................................................. 4
២. រចនាសម្ព័ន្ធកម្មវិធីសិក្សា ..................................................................... 4
៣. លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន ...................................................... 4
៤. មុខវិជ្ជាក្នុងកម្មវិធីសិក្សា ...................................................................... 5
៦. ផែនការដំណើរការកម្មវិធីសិក្សា ............................................................ 8
**ជំពូកទី៣៖ សាស្ត្រាចារ្យ គម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ និងការវាយតម្លៃ** ........................................................................................ 12
១. សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា ................................................................12
២. សាស្ត្រាចារ្យណែនាំគោល និងរង ..........................................................12
៣. ការស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ ........................................ 13
៤. ការវាយតម្លៃការសិក្សា .........................................................................14
៥. ចំណាត់ថ្នាក់ពិន្ទុ.....................................................................................14
៦. លទ្ធផលនៃការសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ.......................... 15
៧. ផែនទីបង្ហាញលទ្ធផលការសិក្សា ក្នុងមុខវិជ្ជានៃកម្មវិធីសិក្សា ...............................17

ជំពូកទី៤៖ ពណ៌នាមុខវិជ្ជា ........................................................................ 19
ឯកសារយោង៖ ........................................................................................ 25
ឧបសម្ព័ន្ធ១៖ អត្ថន័យលេខកូដមុខវិជ្ជា ...................................................... 26

# ជំពូកទី១៖ ព័ត៌មានទូទៅ

## ១. សេចក្តីផ្តើម

កម្ពុជា គឺជាប្រទេសមួយធ្លាប់មានអរិយធម៌ឧត្តុងឧត្តម កិត្យានុភាពខ្ពង់ខ្ពស់ និងការរស់នៅរបស់ប្រជាជនប្រកបដោយភាពថ្លៃថ្នូរ និងស៊ីវីល័យ ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ជាក់ស្តែងនៅចន្លោះឆ្នាំ ១៩៥០ និង១៩៦០ ប្រទេសកម្ពុជាមានការអភិវឌ្ឍខ្លាំង ទាំងផ្នែកសង្គម និងសេដ្ឋកិច្ច ហើយវិស័យអប់រំត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងតំបន់ និងនៅលើពិភពលោក។ ប៉ុន្តែក្នុងរយៈពេលពីរបីទសវត្សចុងក្រោយ កម្ពុជាបានឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ និងទ្រុឌទ្រោមគួរឱ្យសោកស្តាយ។ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ប្រព័ន្ធអប់រំត្រូវបានគេបោះបង់ និងលុបបំបាត់ចោលទាំងស្រុង ហើយគ្រូបង្រៀនប្រមាណ៨០ភាគរយ រងការកាប់សម្លាប់ ធ្វើឱ្យប្រទេសនេះបាត់បង់នូវធនធានមនុស្សប្រកបដោយសក្តានុពលជាច្រើន។

ស្ថិតក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សំដៅបង្កើនគុណភាពធនធានមនុស្ស ជាពិសេសការបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចរបស់បុគ្គលិក និងគណៈគ្រប់គ្រងនៃស្ថាប័នដែលខ្លួនទទួលខុសត្រូវ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំស្តារ និងអភិវឌ្ឍវិស័យអប់រំ ធ្វើឲ្យវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ក្រសួង បានធ្វើកំណែទម្រង់លើវិស័យអប់រំ ដោយបានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយអប់រំជាតិ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីធានាបាននូវការលើកកម្ពស់គុណភាព និងសេវាកម្មអប់រំប្រកបដោយគុណភាព និងសមត្ថភាព ព្រមទាំងស័ក្តិសិទ្ធិភាពនៃបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចដែលជាកត្តាគន្លឹះមិនអាចខ្វះបានក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ និងភាពប្រកួតប្រជែងរបស់ប្រទេសក្នុងពេលបច្ចុប្បន្ន និងសម្រាប់អនាគតរយៈពេលវែង។

ដោយមើលឃើញពីកង្វះខាតនៃអ្នកជំនាញក្នុងការគ្រប់គ្រងគ្រឹះស្ថានអប់រំ និងអ្នកស្រាវជ្រាវផ្នែកអប់រំ ក្រសួងបានលើកទឹកចិត្ត និងប្រគល់ភារកិច្ចឱ្យវិទ្យាស្ថានជាតិអប់រំ បើកដំណើរការកម្មវិធីសិក្សាថ្នាក់**បណ្ឌិតគ្រប់គ្រងអប់រំ ជំនាញគោលនយោបាយអប់រំ និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ** ដោយមានការជួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស សម្ភារៈ និងថវិកា ពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា។ ការដាក់ឱ្យអនុវត្តកម្មវិធីសិក្សានេះ នឹងជួយឱ្យមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ដែលកំពុងបម្រើការងារក្នុងវិស័យអប់រំ មានឱកាសលើកកម្ពស់សមត្ថភាពរបស់ខ្លួនក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

## ២. ឈ្មោះកម្មវិធីសិក្សា

ភាសាខ្មែរ៖ បណ្ឌិតគ្រប់គ្រងអប់រំ

ភាសាអង់គ្លេស៖ Doctor of Philosophy in Educational Administration

## ៣. ចក្ខុវិស័យ

ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំជំនាញគោលនយោបាយអប់រំ និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ គឺដើម្បីបង្កើតចំណេះដឹងថ្មី ទាក់ទងនឹងការគ្រប់គ្រងអប់រំ តាមរយៈការសិក្សាស្រាវជ្រាវ ដើម្បីរួមចំណែក អភិវឌ្ឍសង្គមពុទ្ធិ ប្រកបដោយនិរន្តរភាព។

## ៤. គោលបំណង

ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំជំនាញគោលនយោបាយអប់រំ និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ ត្រូវបានបង្កើតឡើងក្នុងគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយជា៖

១. អ្នកស្រាវជ្រាវការគ្រប់គ្រងអប់រំ អ្នករៀបចំគោលនយោបាយអប់រំ និងអ្នករៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងវិស័យអប់រំ ប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ

២. អ្នកជំនាញគ្រប់គ្រងអប់រំ ដែលមានសមត្ថភាពអនុវត្តទ្រឹស្តីអប់រំក្នុងបរិបទជាតិ តំបន់ និងសកល។

## ៥. លទ្ធផលសិក្សាដែលរំពឹងទុក

អ្នកសិក្សាដែលបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំជំនាញគោលនយោបាយអប់រំ និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំដោយជោគជ័យ គឺជាបុគ្គលដែលមានគុណតម្លៃសម្រាប់សង្គមជាតិ និងពិភពលោក។ អ្នកសិក្សា ត្រូវមានសម្បទាស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (២០១៤) រួមមានចំណេះដឹង ជំនាញការគិតវិភាគ ទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ និងជំនាញលេខនព្វន្តព័ត៌មានវិទ្យា និងទំនាក់ទំនង។ សម្បទាទាំងនេះ មានសេចក្តីលម្អិតដូចខាងក្រោម៖

### ៥.១. ចំណេះដឹង

៥.១.១. យល់ដឹងពីចំណុចសំខាន់ៗ លើការគ្រប់គ្រងអប់រំ រួមមានទ្រឹស្តី គោលការណ៍ និងទស្សនាទានការគ្រប់គ្រងអប់រំជាមូលដ្ឋាន

៥.១.២. យល់ដឹងច្បាស់ពីប្រវត្តិអប់រំ ច្បាប់អប់រំ និងការវិវត្តចុងក្រោយនៃការអប់រំ ជាពិសេសការងារគ្រប់គ្រងអប់រំ និងការគ្រប់គ្រងគ្រឹះស្ថានសិក្សា

៥.១.៣. យល់ដឹងពីការអភិវឌ្ឍជំនាញគ្រប់គ្រងអប់រំ ដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈក្នុងវិស័យអប់រំ។

### ៥.២. ជំនាញការគិតវិភាគ

៥.២.១. ស្រាវជ្រាវលើការងារគ្រប់គ្រងអប់រំ ដើម្បីបង្កើតចំណេះដឹងថ្មីៗ និងដោះស្រាយបញ្ហាផ្សេងៗក្នុងការងារគ្រប់គ្រងអប់រំ និងគ្រប់គ្រងគ្រឹះស្ថានសិក្សាប្រកបដោយគំនិតច្នៃប្រឌិត និងនិរន្តរភាព តាមរយៈការសិក្សាពេញមួយជីវិត

៥.២.២. វិភាគ និងសំយោគទ្រឹស្តី ទស្សនាទាន យុទ្ធសាស្ត្រ និងគោលនយោបាយនានា មកជាផែនការគ្រប់គ្រងអប់រំ សម្រាប់អនុវត្តក្នុងការងារគ្រប់គ្រងអប់រំ និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាប្រកបដោយភាពទន់ភ្លន់ និងប្រសិទ្ធភាពខ្ពស់ ស្របតាមទិសដៅអប់រំជាតិ តំបន់ និងសកល។

**៥.៣. ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ**

៥.៣.១. ប្រព្រឹត្តិយ៉ាងសមស្របជាមួយនឹងស្វ័យភាព និងការផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពជាអ្នកគ្រប់គ្រងអប់រំ

៥.៣.២. ទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន

៥.៣.៣. សម្របសម្រួល និងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការធ្វើការងារជាក្រុម និងអនុវត្តយ៉ាងមានប្រសិទ្ធភាព ក្នុងភាពជាអ្នកដឹកនាំក្នុងវិជ្ជាជីវៈគ្រប់គ្រងអប់រំដ៏ស្មុគស្មាញ

៥.៣.៤. ស្រាវជ្រាវ និងស្វែងរកឫសគល់នៃបញ្ហាទាក់ទងការងារគ្រប់គ្រងអប់រំ ដើម្បីរកដំណោះស្រាយប្រកបដោយសុភវិនិច្ឆ័យ ដោយឈរលើប្រយោជន៍រួមជាមូលដ្ឋាន។

**៥.៤. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង**

៥.៤.១. មានបំណិនក្នុងការប្រើប្រាស់ភាសា និងបច្ចេកវិទ្យាក្នុងការងារទំនាក់ទំនង ការស្វែងរកព័ត៌មានការគ្រប់គ្រងការងារអប់រំ ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញផ្លូវការនិងមិនផ្លូវការ ការបោះពុម្ពផ្សាយ ដូចជានិក្ខេបបទ ឬរបាយការណ៍គម្រោងស្តីពីបញ្ហាសំខាន់ណាមួយប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់។

៥.៤.២. ប្រើប្រាស់ និងវិភាគ នូវព័ត៌មាន ទិន្នន័យគណិតវិទ្យា និងស្ថិតិអប់រំ ។

## ៦. សមត្ថភាពវិជ្ជាជីវៈដែលរំពឹងទុក

អ្នកសិក្សាដែលបំពេញគ្រប់លក្ខខណ្ឌនៃក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាញគោលនយោបាយអប់រំ និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំដោយជោគជ័យ នឹងមានសមត្ថភាពវិជ្ជាជីវៈដូចខាងក្រោម៖

១.ស្រាវជ្រាវដើម្បីរៀបចំបង្កើត កែលម្អ និងអនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រអប់រំ

២. គ្រប់គ្រង និងវាយតម្លៃគ្រឹះស្ថានសិក្សា ស្របតាមការវិវត្តក្នុងបរិបទជាតិ តំបន់ និងសកល

៣. បង្កើត និងដឹកនាំឲ្យមាននវានុវត្តន៍ និងគំនិតច្នៃប្រឌិតផ្នែកគ្រប់គ្រងអប់រំ

៤.វិភាគស៊ីជម្រៅ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងការងារគ្រប់គ្រងអប់រំ

៥. ស្រាវជ្រាវ ចែករំលែក និងបង្រៀនជំនាញគ្រប់គ្រងអប់រំ

## ៧. អាជីពដែលរំពឹងទុក

១. អ្នករៀបចំគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

២. អ្នកគ្រប់គ្រងអង្គភាពអប់រំ និងគ្រឹះស្ថានសិក្សា

៣. អ្នកជំនាញគ្រប់គ្រងអប់រំ និងអ្នកតាមដាន និងវាយតម្លៃការងារគ្រប់គ្រងអប់រំ

៤. អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និងអ្នករៀបចំកម្មវិធីសិក្សាជំនាញគ្រប់គ្រងអប់រំ

# ជំពូកទី២៖
# សេចក្តីលម្អិតកម្មវិធីសិក្សា

## ១. ប្រភេទកម្មវិធីសិក្សា និងចំនួនក្រេឌីត

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំ ផ្តោតលើឯកទេសពីរគឺ គោលនយោបាយអប់រំ (Educational Policy) និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ (Educational Leadership)។ អ្នកសិក្សាអាចជ្រើសរើសប្រកសិក្សាប្រភេទណាមួយនៃកម្មវិធីសិក្សាដូចខាងក្រោម ៖

- ប្រភេទទី ១ ជាកម្មវិធីសិក្សាបែបស្រាវជ្រាវ សរសេរនិក្ខេបបទ សុទ្ធសាធ ប៉ុន្តែអ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនមុខវិជ្ជាបំពេញបន្ថែមចំនួនយ៉ាងតិច១២ក្រេឌីត។
- ប្រភេទទី ២ ជាកម្មវិធីសិក្សាបែបរៀនមុខវិជ្ជា និងសរសេរនិក្ខេបបទ។

អ្នកសិក្សាក្នុងកម្មវិធីសិក្សាទាំងពីរប្រភេទ ត្រូវបំពេញ ៥៧ក្រេឌីត (ក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ២០១៤ កំណត់ ៥៤ក្រេឌីត)។

## ២. រចនាសម្ព័ន្ធកម្មវិធីសិក្សា

| ក្រុមមុខវិជ្ជា | ចំនួនក្រេឌីត | |
|---|---|---|
| | ប្រភេទទី ១ | ប្រភេទទី ២ |
| ១. មុខវិជ្ជាបំពេញបន្ថែម | ១២ | ៦ |
| ២. មុខវិជ្ជាកម្រិតបណ្ឌិត | | |
| ២.១. មុខវិជ្ជារួមនៃឯកទេស | - | ៣ |
| ២.២. មុខវិជ្ជាស្នូលនៃឯកទេស | - | ៦ |
| ៣. មុខវិជ្ជាតម្រង់ទិស | - | ៩ |
| ៤. ការសរសេរ និងការពារនិក្ខេបបទ | | |
| ៤.១ ចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬអន្តរជាតិ | ៦ | ៦ |
| ៤.២ ធ្វើបទបង្ហាញក្នុងវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ | ៣ | ៣ |
| ៤.៣ ធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ | ៣ |
| ៤.៤ ការពារគម្រោងស្រាវជ្រាវពិស្តារ | ៣ | ៣ |
| ៤.៥ និក្ខេបបទ | ៣០ | ១៨ |
| **សរុបចំនួនក្រេឌីត** | **៥៧** | **៥៧** |

## ៣. លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន

ការដាក់ពាក្យចូលសិក្សាក្នុងកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំ អ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌចូលរៀនគ្រប់ចំណុចដែលបានកំណត់ដោយគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សាដូចខាងក្រោម៖

### ៣.១. កម្មវិធីសិក្សាប្រភេទទី១

- ត្រូវមានស្នាដៃបោះពុម្ពយ៉ាងតិច ២អត្ថបទ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ក្នុងព្រឹត្តិបត្រឬទស្សនាវដ្ដីស្រាវជ្រាវ (Peer Review Journals)
- បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយសរសេរសារណា ពីគ្រឹះស្ថានសិក្សាដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងមានពិន្ទុសិក្សា (GPA) មិនតិចជាង៣.០០ នៃប្រព័ន្ធ ៤.០០ ឬមធ្យមភាគសមមូល (៧០% ឡើង)
- មានសំណើគម្រោងស្រាវជ្រាវបឋម
- មានបទពិសោធន៍លើការងារស្រាវជ្រាវផ្នែកអប់រំយ៉ាងតិច ២ឆ្នាំ ឬមានបទពិសោធន៍ក្នុងការងារអប់រំយ៉ាងតិច ៥ឆ្នាំ
- មានសមត្ថភាពភាសាអង់គ្លេសកំណត់ដោយកម្មវិធី IELTS ពិន្ទុ ៥.0 ឬសមមូល ឬភាសាបារាំងកំណត់កម្រិត DELF ឬTCF B2Test ឬ ជាប់ការប្រឡងរៀបចំដោយវិទ្យាស្ថានជាតិអប់រំ
- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និង
- មានលក្ខណៈសម្បត្តិផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា។

### ៣.២. កម្មវិធីសិក្សាប្រភេទទី២

- បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយសរសេរសារណា ពីគ្រឹះស្ថានសិក្សាដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងមានពិន្ទុសិក្សា (GPA) មិនតិចជាង៣.០០ នៃប្រព័ន្ធ ៤.០០ ឬមធ្យមភាគសមមូល (៧០% ឡើង)
- មានសំណើគម្រោងស្រាវជ្រាវបឋម
- មានសមត្ថភាពភាសាអង់គ្លេសកំណត់ដោយកម្មវិធី IELTS ពិន្ទុ ៥.0 ឬសមមូល ឬភាសាបារាំងកំណត់កម្រិត DELF ឬTCF B2Test ឬជាប់ការប្រឡងរៀបចំដោយវិទ្យាស្ថានជាតិអប់រំ
- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និង
- មានលក្ខណៈសម្បត្តិផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា។

## ៤. មុខវិជ្ជាក្នុងកម្មវិធីសិក្សា

### ៤.១. កម្មវិធីសិក្សាប្រភេទទី១

| | | |
|---|---|---|
| **ក. មុខវិជ្ជាបំពេញបន្ថែម** | **យ៉ាងតិច** | **១២ ក្រេឌីត** |
| ១. ១០១១០០ | ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព<br>Principle of Education for Sustainable Development | ៣ (៣-០-៩) |
| ២. ១០១១០១ | មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ<br>Fundamentals of Educational Research | ៣ (៣-០-៩) |
| ៣. ១០១២៥១ | វិធីសាស្ត្រស្រាវជ្រាវអប់រំកម្រិតខ្ពស់ | ៣ (៣-០-៩) |

Advanced Research Methodology in Education

៤. ១០១ ៣០៥ ការស្រាវជ្រាវផ្នែកគ្រប់គ្រងអប់រំដើម្បីអភិវឌ្ឍប្រទេស ៣ (៣-០-៩)

Research in Educational Management for National Development

**ខ. ការសរសេរ និងការពារនិក្ខេបបទ** **៤៥ ក្រេឌីត**

១. ១០១៥០០ និក្ខេបបទ ១ ៣ ក្រេឌីត

២. ១០១៥០១ និក្ខេបបទ ២ ៣ ក្រេឌីត

៣. ១០១៥០២ និក្ខេបបទ ៣ ៣ ក្រេឌីត

៤. ១០១៥០៣ និក្ខេបបទ ៤ ៦ ក្រេឌីត

៥. ១០១៥០៤ និក្ខេបបទ ៥ ៩ ក្រេឌីត

៦. ១០១៥០៥ និក្ខេបបទ ៦ ៩ ក្រេឌីត

៧. ចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬអន្តរជាតិ (២ អត្ថបទ) ៦ ក្រេឌីត

៨. ធ្វើបទបង្ហាញក្នុងវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ ៣ ក្រេឌីត

៩. ធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ៣ ក្រេឌីត

**៤.២. កម្មវិធីសិក្សាប្រភេទទី២**

**ក. មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម** **៦ ក្រេឌីត**

១. ១០១១០០ ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ៣ (៣-០-៩)

Education for Sustainable Development

២. ១០១១០១ មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ ៣ (៣-០-៩)

Fundamentals of Educational Research

**ខ. មុខវិជ្ជាកម្រិតបណ្ឌិត (រួមនៃឯកទេស)** **៣ ក្រេឌីត**

១. ១០១២៥១ វិធីសាស្ត្រការស្រាវជ្រាវអប់រំកម្រិតខ្ពស់ ៣ (៣-០-៩)

Advanced Research Methodology in Education

២. ១០១២០១ ភាសាអង់គ្លេសសម្រាប់អំណានកម្រិតខ្ពស់ S/U (៣-០-៩)

Advanced English for Reading (Non-Credit)

៣. ១០១២០២ ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់ S/U (៣-០-៩)

Advanced English for Writing (Non-Credit)

**គ. មុខវិជ្ជាកម្រិតបណ្ឌិត (ស្នូលនៃឯកទេស)** **៦ ក្រេឌីត**

១. ១០១ ២០០ការវិភាគស៊ីជម្រៅលើការងារអប់រំ ៣ (៣-០-៩)

Critical Analysis in Education

២. ១០១៣០១ បញ្ហានិងនិន្នាការក្នុងផ្នែកគ្រប់គ្រងអប់រំ ៣ (៣-០-៩)

Current Issues and Trends in Educational Management

៣. ១០១២៥២ តម្រង់ទិសការស្រាវជ្រាវ (សិក្ខាសាលានិក្ខេបបទ) S/U (៣-០-៩)

Doctoral Dissertation Seminar (Non-Credit)

**ឃ. មុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ ៩ ក្រេឌីត**

**សម្រាប់អ្នកសិក្សាដែលជ្រើសរើសឯកទេស គោលនយោបាយអប់រំ**

១. ១០១៣០០ ការអភិវឌ្ឍគោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ ៣ (៣-០-៩)

Developing Educational Policy and Strategic Management

២. ១០១៣០៥ ការស្រាវជ្រាវផ្នែកគ្រប់គ្រងអប់រំដើម្បីអភិវឌ្ឍប្រទេសជាតិ ៣ (៣-០-៩)

Research in Education Management for National Development

៣. ១០១៣០២ ការអភិវឌ្ឍការគ្រប់គ្រងអប់រំដើម្បីសហគមន៍សកល ២ (២-០-៦)

Developing Educational Management for Global Community

៤. ១០១៣០៣ ការអភិវឌ្ឍបទដ្ឋានអាជីពគ្រប់គ្រងអប់រំ ២ (២-០-៦)

Developing Professional Standards of Educational Management

៥. ១០១៣០៤ ការអភិវឌ្ឍការគ្រប់គ្រងទូទៅ ថវិកា គណនេយ្យនិងផែនការអប់រំ ៣ (៣-០-៩)

Developing General, Budgeting & Financial Management&Planning

៦. ១០១៣០៦ ស្វ័យសិក្សា Individual Study ២ (០-០-៦)

**សម្រាប់អ្នកសិក្សាដែលជ្រើសរើសឯកទេស ភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ**

១. ០១៣០៧ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដើម្បីការផ្លាស់ប្តូរក្នុងវិស័យអប់រំ ៣ (៣-០-៩)

Leadership and Change Management in Education

២. ១០១៣០៨ ការគ្រប់គ្រងកម្មវិធីសិក្សា Curriculum Management ៣ (៣-០-៩)

៣. ១០១៣១០ ការគ្រប់គ្រងនវានុវត្តន៍ និងគំនិតច្នៃប្រឌិតផ្នែកអប់រំ ២ (២-០-៦)

Management of Innovation and Creativity in Education

៤. ១០១៣១១ ក្រមសីលធម៌អ្នកដឹកនាំលើវិស័យអប់រំ ៣ (៣-០-៩)

Ethics for Educational Leaders

៥. ១០១៣១២ ការសិក្សាប្រៀបធៀបផ្នែកគ្រប់គ្រងអប់រំ ៣ (៣-០-៩)

Comparative Study in Educational Management

៦. ១០១៣១៣ ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ៣ (៣-០-៩)

Human Resource Management in Education

៧. ១០១៣១៤ ការគ្រប់គ្រងការអប់រំបច្ចេកទេស ៣ (៣-០-៩)

Administration of Vocational and Technical Education

ឃ. ការសរសេរ និងការពារនិក្ខេបបទ ៣៣ ក្រេឌីត

១. ១០១៥២៥ និក្ខេបបទ១ ៦ ក្រេឌីត

២. ១០១៥២៦ និក្ខេបបទ២ ៦ ក្រេឌីត

៣. ១០១៥២៧ និក្ខេបបទ៣ ៦ ក្រេឌីត

៤. ចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬអន្តរជាតិ (២អត្ថបទ) ៦ ក្រេឌីត

៥. ធ្វើបទបង្ហាញក្នុងវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ ៣ ក្រេឌីត

៦. ធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ៣ ក្រេឌីត

ក្រៅពីមុខវិជ្ជាខាងលើនេះ អ្នកសិក្សាអាចចុះឈ្មោះចូលរៀនមុខវិជ្ជាផ្សេងដែលបើកបង្រៀនដោយវិទ្យាស្ថានជាតិអប់រំបាន ដោយមានការឯកភាពពីគ្រូណែនាំ ឬគ្រូទីប្រឹក្សា និងគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា។

## ៥. ការប្រឡងវាស់ស្ទង់គុណសម្បត្តិ

១០១៥៥០ ការប្រឡងវាស់ស្ទង់គុណសម្បត្តិ S/U (មិនមានក្រេឌីត)
Qualifying Exam (QE)

ការប្រឡងវាស់ស្ទង់គុណសម្បត្តិ ផ្តោតលើមុខវិជ្ជាកម្រិតបណ្ឌិត (មុខវិជ្ជារួម និងស្នូលនៃឯកទេស) នឹងត្រូវធ្វើឡើងនៅមុនបំណាច់ឆមាសទី១ នៃឆ្នាំទី២ បន្ទាប់ពីអ្នកសិក្សាបានសិក្សាយ៉ាងតិច ១៨ក្រេឌីត។ ក្នុងករណីអ្នកសិក្សាប្រឡងធ្លាក់ការប្រឡងវាស់ស្ទង់គុណសម្បត្តិ អ្នកសិក្សាអាច ដាក់ពាក្យប្រឡងជាថ្មីរយៈពេល ១ខែ ក្រោយថ្ងៃប្រកាសលទ្ធផល។ បន្ទាប់ពីជាប់ការប្រឡងវាស់ស្ទង់ គុណសម្បត្តិអ្នកសិក្សា នឹងក្លាយជាបេក្ខជនថ្នាក់បណ្ឌិត (Ph.D Candidate)។ បន្ទាប់ពីនេះ អ្នកសិក្សាអាចស្នើប្រឡងការពារគម្រោងស្រាវជ្រាវបឋម (Proposal)។ ក្រោយពីទទួលបានការអនុម័ត គម្រោងស្រាវជ្រាវពីគណៈកម្មការប្រឡង អ្នកសិក្សាមានពេលវេលាយ៉ាងតិច ២១ ខែសម្រាប់បញ្ចប់ ការងារនិក្ខេបបទរបស់ខ្លួន។

## ៦. ផែនការដំណើរការកម្មវិធីសិក្សា

### ៦.១. ពេលវេលាដំណើរការកម្មវិធីសិក្សា

កិច្ចដំណើរការកម្មវិធីសិក្សាថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអប់រំ អាចរៀបចំឡើងជាថ្នាក់ពេញម៉ោង និងក្រៅម៉ោង តាមពេលវេលាដូចខាងក្រោម៖

| ប្រភេទថ្នាក់ | រយៈពេល |
|---|---|
| ពេញម៉ោង | ៣-៦ឆ្នាំ |
| ក្រៅម៉ោង | ៣-៨ឆ្នាំ |

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំផ្នែកគ្រប់គ្រងអប់រំ ជាកម្មវិធីដែលដំណើរការបង្រៀន ២ឆមាសក្នុងមួយឆ្នាំសិក្សា។ ក្នុង១ឆមាស មានរយៈពេលយ៉ាងតិច១៥សប្តាហ៍ ដោយកំណត់កាលបរិច្ឆេទសិក្សាដូចខាងក្រោម៖

- ឆមាសទី១៖ វិច្ឆិកា-កុម្ភៈ (អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)
- ឆមាសទី២៖ មិនា-កក្កដា (អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)
- វិស្សមកាលធំ៖សីហា-តុលា (អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)

### ៦.២ ការចុះឈ្មោះរៀនក្នុងឆមាស

## កម្មវិធីសិក្សាប្រភេទទី១

| ឆមាស | លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| ០ (ត្រៀម) | ១០១១០១ | មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ | ៣ (៣-០-៩) | **បំពេញបន្ថែម** |
| | ១០១១០០ | ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព | ៣ (៣-០-៩) | |
| | ១០១២៥១ | វិធីសាស្ត្រការស្រាវជ្រាវអប់រំកម្រិតខ្ពស់ | ៣ (៣-០-៩) | |
| | ១០១៣០៥ | ការស្រាវជ្រាវផ្នែកគ្រប់គ្រងអប់រំដើម្បីការអភិវឌ្ឍប្រទេស | ៣ (៣-០-៩) | |

| ឆមាស | លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| | | **ឆ្នាំទី១** | | |
| ១ | ១០១៥០០ | និក្ខេបបទ១ | ៣ | និក្ខេបបទ |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលឯកទេស |
| ២ | ១០១៥០១ | និក្ខេបបទ២ | ៣ | និក្ខេបបទ |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលឯកទេស |
| | | **ឆ្នាំទី២** | | |
| ១ | ១០១៥០២ | និក្ខេបបទ៣ | ៣ | និក្ខេបបទ |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលឯកទេស |
| | ១០១៥៥០ | **ប្រឡងវាស់ស្ទង់គុណសម្បត្តិ** | S/U | ចាំបាច់ |
| ២ | ១០១៥០៣ | និក្ខេបបទ៤ | ៦ | និក្ខេបបទ |
| | | **ឆ្នាំទី៣** | | |
| ១ | ១០១៥០៤ | និក្ខេបបទ៥ | ៩ | និក្ខេបបទ |

| ឆមាស | លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| ២ | ១០១៥០៥ | និក្ខេបបទ៦ | ៩ | និក្ខេបបទ |

## កម្មវិធីសិក្សាប្រភេទទី២

## ឯកទេសៈ គោលនយោបាយអប់រំ

| ឆមាស | លេខកូដមុខវិជ្ជា | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| **ឆ្នាំទី១** | | | | |
| ១ | ១០១១០០ | ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព | ៣ (៣-០-៩) | បំពេញបន្ថែម |
| | ១០១១០១ | មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ | ៣ (៣-០-៩) | បំពេញបន្ថែម |
| | ១០១២០០ | ការវិភាគស៊ីជម្រៅលើការអប់រំ | ៣ (៣-០-៩) | ស្នូលនៃឯកទេស |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលនៃឯកទេស |
| ២ | ១០១៣០១ | បញ្ហានិងនិន្នាការក្នុងផ្នែកគ្រប់គ្រងអប់រំ | ៣ (៣-០-៩) | ស្នូលនៃឯកទេស |
| | ១០១២០១ | ភាសាអង់គ្លេសសម្រាប់ការអានកម្រិតខ្ពស់ | S/U (៣-០-៩) | រួមនៃឯកទេស |
| | ១០១២០២ | វិធីសាស្ត្រការស្រាវជ្រាវអប់រំកម្រិតខ្ពស់ | ៣ (៣-០-៩) | រួមនៃឯកទេស |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលនៃឯកទេស |
| **ឆ្នាំទី២** | | | | |
| ១ | ១០១៣០០ | ការអភិវឌ្ឍគោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ | ៣ (៣-០-៩) | តម្រង់ទិស |
| | ១០១៣០៥ | ការស្រាវជ្រាវផ្នែកគ្រប់គ្រងអប់រំដើម្បីការអភិវឌ្ឍប្រទេស | ៣ (៣-០-៩) | តម្រង់ទិស |
| | ១០១៣០៣ | ការអភិវឌ្ឍបទដ្ឋានអាជីពគ្រប់គ្រងអប់រំ | ៣ (៣-០-៩) | តម្រង់ទិស |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលនៃឯកទេស |
| | ១០១៥៥០ | **ប្រឡងវាស់ស្ទង់គុណសម្បត្តិ** | S/U | ប្រឡងQE |
| ២ | ១០១២០២ | ភាសាអង់គ្លេសសម្រាប់សំណេរ | S/U (៣-០-៩) | រួមនៃឯកទេស |

| ឆមាស | លេខកូដមុខវិជ្ជា | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| | | កម្រិតខ្ពស់ | | |
| | ១០១៥២៥ | និក្ខេបបទ១ | ៦ | និក្ខេបបទ |
| **ឆ្នាំទី៣** | | | | |
| ១ | ១០១៥២៦ | និក្ខេបបទ២ | ៦ | និក្ខេបបទ |
| ២ | ១០១៥២៧ | និក្ខេបបទ៣ | ៦ | និក្ខេបបទ |

## កម្មវិធីសិក្សាប្រភេទទី២

## ឯកទេសៈ ភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ

| ឆមាស | លេខកូដមុខវិជ្ជា | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| **ឆ្នាំទី១** | | | | |
| ១ | ១០១១០០ | ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព | ៣ (៣-០-៩) | បំពេញបន្ថែម |
| | ១០១១០១ | មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ | ៣ (៣-០-៩) | បំពេញបន្ថែម |
| | ១០១២០០ | ការវិភាគស៊ីជម្រៅលើការអប់រំ | ៣ (៣-០-៩) | ស្នូលនៃឯកទេស |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលនៃឯកទេស |
| ២ | ១០១៣០១ | បញ្ហានិងនិន្នាការក្នុងផ្នែកគ្រប់គ្រងអប់រំ | ៣ (៣-០-៩) | ស្នូលនៃឯកទេស |
| | ១០១២០១ | ភាសាអង់គ្លេសម្រាប់អំណានកម្រិតខ្ពស់ | S/U (៣-០-៩) | រួមនៃឯកទេស |
| | ១០១២០២ | វិធីសាស្ត្រការស្រាវជ្រាវអប់រំកម្រិតខ្ពស់ | ៣ (៣-០-៩) | រួមនៃឯកទេស |
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U (៣-០-៩) | ស្នូលនៃឯកទេស |
| **ឆ្នាំទី២** | | | | |
| ១ | ១០១៣០៧ | ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងដើម្បីការផ្លាស់ប្តូរក្នុងវិស័យអប់រំ | ៣ (៣-០-៩) | តម្រង់ទិស |
| | ១០១៣១៤ | ការគ្រប់គ្រងការអប់រំបច្ចេកទេស | ៣ (៣-០-៩) | តម្រង់ទិស |
| | ១០១៣១៣ | ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ | ៣ (៣-០-៩) | តម្រង់ទិស |

| ឆមាស | លេខកូដមុខវិជ្ជា | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| | ១០១២៥២ | តម្រង់ទិសការស្រាវជ្រាវ | S/U ( ៣-០-៩ ) | ស្នូលនៃឯកទេស |
| | ១០១ ៥៥០ | **ប្រឡងវាស់ស្ទង់គុណសម្បត្តិ** | S/U | ចាំបាច់ |
| ២ | ១០១៥២៥ | និក្ខេបបទ១ | ៦ | និក្ខេបបទ |
| | ១០១២០២ | ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់ | S/U ( ៣-០-៩ ) | រួមនៃឯកទេស |
| | | **ឆ្នាំទី៣** | | |
| ១ | ១០១៥២៦ | និក្ខេបបទ២ | ៦ | និក្ខេបបទ |
| ២ | ១០១៥២៧ | និក្ខេបបទ៣ | ៦ | និក្ខេបបទ |

# ជំពូកទី៣៖
# សាស្ត្រាចារ្យ គម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ និងការវាយតម្លៃ

## ១. សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា

សាស្ត្រាចារ្យដែលត្រូវបង្រៀនថ្នាក់បណ្ឌិតអប់រំជំនាញគ្រប់គ្រងអប់រំត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានសញ្ញាបត្របណ្ឌិតលើជំនាញគ្រប់គ្រងអប់រំឬជំនាញសមស្រប ឬបទពិសោធន៍គ្រប់គ្រាន់ពាក់ព័ន្ធនឹងមុខវិជ្ជាដែលខ្លួនទទួលបន្ទុកបង្រៀន ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- មានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន
- មានចរិយាសម្បត្តិ សីលធម៌ មនសិការវិជ្ជាជីវៈ និងមានភាពជាគ្រូបង្រៀន។

## ២. សាស្ត្រាចារ្យណែនាំគោល និងរង

សាស្ត្រាចារ្យណែនាំត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានសញ្ញាបត្របណ្ឌិត និងមានបទពិសោធន៍ការងារស្រាវជ្រាវយ៉ាងតិច ៣ឆ្នាំ
- មានស្នាដៃ និងកិត្តិនាមក្នុងការចុះផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រជាតិ និងអន្តរជាតិ
- មានស្មារតីទទួលខុសត្រូវក្នុងការណែនាំការស្រាវជ្រាវវិទ្យាសាស្ត្រ
- មានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន
- មានចរិយាសម្បត្តិ សីលធម៌ មនសិការវិជ្ជាជីវៈ និងមានភាពជាគ្រូបង្រៀន។

## ៣. ការស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំតម្រូវឱ្យអ្នកសិក្សាដែលចុះឈ្មោះរៀនក្នុងកម្មវិធីទាំងប្រភេទទី១ និង ប្រភេទទី២ សរសេរនិក្ខេបបទ ដើម្បីបញ្ចប់ការសិក្សាដោយផ្អែកលើលក្ខខណ្ឌកំណត់ដោយកម្មវិធីសិក្សានៃវិទ្យាស្ថានជាតិអប់រំ។

### ៣.១. លក្ខណៈសម្បត្តិសម្រាប់ការស្រាវជ្រាវសរសេរនិក្ខេបបទ

ដើម្បីស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទបាន អ្នកសិក្សាត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានចំណេះដឹងស៊ីជម្រៅលើផ្នែកគ្រប់គ្រងអប់រំ
- មានវិធីសាស្ត្រធ្វើការងារស្រាវជ្រាវបានយ៉ាងល្អ
- មានសីលធម៌វិជ្ជាជីវៈក្នុងការងារស្រាវជ្រាវ
- មានសមត្ថភាពគិត វិភាគនិងដោះស្រាយបញ្ហាដែលកើតឡើងក្នុងការងារស្រាវជ្រាវប្រកបដោយភាពឯករាជ្យ
- មានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ភាសាជាតិ និងភាសាអន្តរជាតិដើម្បីស្វែងរកព័ត៌មានសម្រាប់គាំទ្រការងារស្រាវជ្រាវ
- មានសុខភាពល្អ អាចបំពេញការងារបានប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលធ្វើការងារស្រាវជ្រាវសរសេរនិក្ខេបបទ។

### ៣.២. រយៈពេល

- អ្នកសិក្សាចុះឈ្មោះរៀនក្នុងកម្មវិធីសិក្សាទាំង២ប្រភេទ ត្រូវស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទយ៉ាងយូរមុនដំណាច់ឆ្នាំសិក្សាទី២។
- គម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ ត្រូវទទួលបានការអនុម័តពីគណៈកម្មការយ៉ាងយូរបំផុតមិនឱ្យលើសឆមាសទី ២ឆ្នាំទី ៣។

### ៣.៣. ចំនួនក្រេឌីតការងារស្រាវជ្រាវ (សរសេរនិក្ខេបបទ)

- កម្មវិធីសិក្សាប្រភេទទី១ មានចំនួន ៣៣ ក្រេឌីត
- កម្មវិធីសិក្សាប្រភេទទី២ មានចំនួន ២១ ក្រេឌីត

### ៣.៤. ការត្រៀម

ដើម្បីឱ្យកិច្ចដំណើរការអនុវត្តកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំទទួលបានលទ្ធផលល្អប្រសើរ គណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សាត្រូវត្រៀមលក្ខណៈដូចខាងក្រោម៖

- តែងតាំង ឬចាត់តាំងសាស្ត្រាចារ្យណែនាំគោល និងរង សម្រាប់ដឹកនាំអ្នកសិក្សាស្រាវជ្រាវសរសេរនិក្ខេបបទ

- ក្នុងឆមាសនីមួយៗ អ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនមុខវិជ្ជាសិក្ខាសាលានិក្ខេបបទថ្នាក់បណ្ឌិត។ លក្ខខណ្ឌនៃកម្មវិធីសិក្សាតម្រូវឱ្យនិស្សិតស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ និងរាយការណ៍អំពីវឌ្ឍនភាពការស្រាវជ្រាវជារៀងរាល់ឆមាសដើម្បីពិនិត្យតាមដានការធ្វើការងាររបស់អ្នកសិក្សា និងដើម្បីធានាបានអ្នកសិក្សាអាចបញ្ចប់ការសិក្សាតាមកាលបរិច្ឆេទសិក្សាបានកំណត់។

## ៤. ការវាយតម្លៃការសិក្សា

ការវាយតម្លៃកាសិក្សាទូទៅ និងការប្រឡងការពារនិក្ខេបបទ ត្រូវអនុវត្តតាមលក្ខខណ្ឌរបស់វិទ្យាស្ថានជាតិអប់រំដែលបានកំណត់ ដោយផ្អែកលើសេចក្តីណែនាំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៥. ចំណាត់ថ្នាក់ពិន្ទុ

| ពិន្ទុតាមកម្រិត | សមាសភាគភាគរយ | សញ្ញាពិន្ទុជាអក្សរ | ការបរិយាយ |
|---|---|---|---|
| ៤.00 | ៨៥-១00 | A | ល្អប្រសើរ |
| ៣.៥0 | ៨0-៨៤ | B+ | ល្អណាស់ |
| ៣.00 | ៧0-៧៩ | B | ល្អ |
| ២.៥0 | ៦៥-៦៩ | C+ | ល្អបង្គួរ |
| ២.00 | ៥0-៦៤ | C | មធ្យម |
| ១.៥0 | ៤៥-៤៩ | D+ | ខ្សោយ |
| ១.00 | ៤0-៤៤ | D | ខ្សោយណាស់ |
| 0.00 | 0-៣៩ | F | ធ្លាក់ |

កំណត់សម្គាល់៖ អ្នកសិក្សាត្រូវមានមធ្យមភាគពិន្ទុមិនទាបជាង៣.00 ឬនិទ្ទេសB។

## ៦. លទ្ធផលនៃការសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ

| លទ្ធផលនៃការសិក្សា | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
|---|---|---|
| **ចំណេះដឹង (Knowledge)៖**<br>១. យល់ដឹងពីចំណុចសំខាន់ៗស្តីពីការគ្រប់គ្រងអប់រំរួមមាន ទ្រឹស្តី គោលការណ៍និងទស្សនាទានការគ្រប់គ្រងអប់រំជាមូលដ្ឋាន<br>២. យល់ដឹងច្បាស់ពីប្រវត្តិអប់រំ ច្បាប់អប់រំនិងការវិវត្តចុងក្រោយនៃការអប់រំ ជាពិសេសការងារគ្រប់គ្រងអប់រំ និងការគ្រប់គ្រងគ្រឹះស្ថានសិក្សា<br>៣. យល់ដឹងពីការអភិវឌ្ឍជំនាញគ្រប់គ្រងអប់រំ ដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈក្នុងវិស័យអប់រំ។ | បង្រៀនដោយវិធី<br>- Inquiry-Based, Seminar<br>- Critical Analysis<br>- Synthesis<br>- Problem-Based<br>- Research-Based<br>- Self-Directed | វាយតម្លៃតាមរយៈ៖<br>- ការប្រឡង ការធ្វើតេស្ត<br>- ការត្រួតពិនិត្យលើស្នាដៃលទ្ធផលការងារ<br>- ការត្រួតពិនិត្យលើការធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវ និងនវានុវត្តផ្សេងៗ |
| **ជំនាញការគិតវិភាគ(Cognitive)៖**<br>១. ស្រាវជ្រាវលើការងារគ្រប់គ្រងអប់រំដើម្បីបង្កើតចំណេះដឹងថ្មីៗ និងដោះស្រាយបញ្ហាផ្សេងៗក្នុងការងារគ្រប់គ្រងអប់រំនិងគ្រប់គ្រងគ្រឹះស្ថានសិក្សាប្រកបដោយគំនិតច្នៃប្រឌិត និងនិរន្តរភាព តាមរយៈការសិក្សាពេញមួយជីវិត។<br>២. វិភាគ និងសំយោគទ្រឹស្តី ទស្សនាទាន យុទ្ធសាស្ត្រ និងគោលនយោបាយនានា មកជាផែនការគ្រប់គ្រងអប់រំ សម្រាប់អនុវត្តក្នុងការងារគ្រប់គ្រងអប់រំ និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាប្រកបដោយភាពទន់ភ្លន់និងប្រសិទ្ធភាពខ្ពស់ស្របតាមទិសដៅអប់រំជាតិ តំបន់ និងសាកល។ | បង្រៀនដោយផ្តោតលើការអនុវត្តដែលប្រើប្រាស់វិធីសាស្ត្រ<br>- Case Study, Seminar<br>- Critical Analysis<br>- Synthesis<br>- Problem-Based<br>- Research-Based<br>- Self-Directed<br>- Lecture, Project-based | វាយតម្លៃតាមរយៈ៖<br>- ការសង្កេតឥរិយាបទចំពោះការសិក្សា និងការងារដែលខ្លួនទទួលខុសត្រូវ<br>- ការពិនិត្យដោះស្រាយបញ្ហាក្នុងស្ថានភាពជាក់ស្តែង<br>- ការត្រួតពិនិត្យលើការធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវ និងនវានុវត្តផ្សេងៗ |

| លទ្ធផលនៃការសិក្សា | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
| --- | --- | --- |
| **ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ** ( Interpersonal Skills and Responsibilities )៖<br>១. ប្រព្រឹត្តិយ៉ាងសមស្របជាមួយនឹងស្វ័យភាពនិងការផ្ដើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពជាអ្នកគ្រប់គ្រងអប់រំ<br>២. ទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន<br>៣. សម្របសម្រួលនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការធ្វើការងារជាក្រុម និងអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងវិជ្ជាជីវៈគ្រប់គ្រងអប់រំដ៏ស្មុគស្មាញ<br>៤. ស្រាវជ្រាវ និងស្វែងរកឫសគល់នៃបញ្ហាទាក់ទងការងារគ្រប់គ្រងអប់រំដើម្បីរកដំណោះស្រាយប្រកបដោយសុភវិនិច្ឆ័យ ដោយឈរលើប្រយោជន៍រួមជាមូលដ្ឋាន។ | បង្រៀនដោយរៀបចំសកម្មភាពបង្រៀនបង្កលក្ខណៈឱ្យអ្នកសិក្សាធ្វើការជាក្រុម និងជាបុគ្គល | វាយតម្លៃតាមរយៈការសង្កេតឥរិយាបទ ការចូលរួមការងារក្នុងក្រុម និងការធ្វើការងារដែលខ្លួនទទួលខុសត្រូវ |
| **ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង** ( Numeric Skill, Information Technology and Communication )៖<br>១. មានបំណិនក្នុងការប្រើប្រាស់ភាសា និងបច្ចេកវិទ្យាក្នុងការងារទំនាក់ទំនង ការស្វែងរកព័ត៌មានការគ្រប់គ្រងការងារអប់រំ ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញផ្លូវការនិងមិនផ្លូវការ ការបោះពុម្ពផ្សាយ ដូចជានិក្ខេបបទ ជំនាញឬរបាយការណ៍គម្រោងស្ដីពីបញ្ហាសំខាន់និងស្មុគស្មាញណាមួយប្រកបដោយតម្លាភាពនិងការទទួលខុសត្រូវខ្ពស់។ | បង្រៀនដោយប្រើប្រាស់ប្រើប្រាស់បច្ចេកវិទ្យាក្នុងការស្វែងរកឯកសារ ការវិភាគសំយោគទិន្នន័យទាំងបែបគុណភាព និងបែបបរិមាណ ការធ្វើការជាក្រុម ការធ្វើបទបង្ហាញមតិយោបល់ និងលទ្ធផលការងារ។ | វាយតម្លៃដោយ៖<br>- ពិនិត្យលើលទ្ធផលការងារដែលខ្លួនទទួលខុសត្រូវ ដូចជា Working Paper, Project ជាដើម<br>- ពិនិត្យលើការប្រើប្រាស់ទិន្នន័យ និងស្ថិតិ |

| លទ្ធផលនៃការសិក្សា | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
|---|---|---|
| ២. ប្រើប្រាស់និងវិភាគយ៉ាងមានប្រសិទ្ធភាពនូវព័ត៌មាន ទិន្នន័យ គណិតវិទ្យា និងស្ថិតិ ។ | | - ពិនិត្យលើសមត្ថភាពការប្រើប្រាស់បច្ចេកវិទ្យាដើម្បីស្វែងរកចំណេះដឹង និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ |

## ៧. ផែនទីបង្ហាញលទ្ធផលការសិក្សា ក្នុងមុខវិជ្ជានៃកម្មវិធីសិក្សា

| ប្រភេទមុខវិជ្ជា | មុខវិជ្ជា | ១. ចំណេះដឹង | | | ២.ការគិតវិភាគ | | ៣.ទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | | | | ៤.លេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១.១ | ១.២ | ១.៣ | ២.១ | ២.២ | ៣.១ | ៣.២ | ៣.៣ | ៣.៤ | ៤.១ | ៤.២ |
| **បំពេញបន្ថែម** | ១.ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព | ✓ | ✓ | ✓ | ✓ | ✓ | ✓ | * | * | * | * | |
| | ២.មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ | * | * | * | * | * | ✓ | * | * | ✓ | ✓ | ✓ |
| **រួមនៃឯកទេស** | ១.ការវិភាគស៊ីជម្រៅលើការអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | * | * | * | * | * | * |
| | ២. ភាសាអង់គ្លេសសម្រាបការអានកម្រិតខ្ពស់ | * | * | * | * | * | * | * | * | * | ✓ | * |
| | ៣. ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់ | * | * | * | * | * | * | * | * | * | ✓ | * |
| **ស្នូលឯកទេស** | ១. ស្ថិតិអនុវត្តសម្រាប់ការស្រាវជ្រាវអប់រំ | * | * | * | * | * | * | ✓ | * | ✓ | ✓ | ✓ |
| | ២. វិធីសាស្ត្រស្រាវជ្រាវអប់រំកម្រិតខ្ពស់ ** | * | * | * | * | * | ✓ | * | * | ✓ | ✓ | ✓ |
| | ៣. សិក្ខាសាលានិក្ខេបបទ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| **តម្រង់ទិស** | ១. បញ្ហានិងនិន្នាការក្នុងផ្នែកគ្រប់គ្រងអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | * | * | * | * | * | * |

| ប្រភេទមុខវិជ្ជា | មុខវិជ្ជា | ១. ចំណេះដឹង | | | ២.ការគិតវិភាគ | | ៣.ទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | | | | ៤.លេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១.១ | ១.២ | ១.៣ | ២.១ | ២.២ | ៣.១ | ៣.២ | ៣.៣ | ៣.៤ | ៤.១ | ៤.២ |
| និង ការប្រឡង ទូទៅ | ២. ការអភិវឌ្ឍគោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | * | * | * | ✓ | ✓ | ✓ |
| | ៣. ការស្រាវជ្រាវផ្នែកគ្រប់គ្រងអប់រំដើម្បីអភិវឌ្ឍប្រទេស ** | ✓ | ✓ | ✓ | ✓ | ✓ | * | * | * | ✓ | * | ✓ |
| | ៤. ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដើម្បីការផ្លាស់ប្តូរក្នុងវិស័យអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | * | * | ✓ | ✓ | * | * |
| | ៥. ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | * | ✓ | ✓ | * | * | * |
| **និក្ខេបបទ** | ១. និក្ខេបបទ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| **ការប្រឡងQE** | ១. ប្រឡងវាស់ស្ទង់គុណសម្បត្តិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

✓ ផ្ទាល់ *មិនផ្ទាល់ ** មុខវិជ្ជាបំពេញបន្ថែមក្នុងកម្មវិធីសិក្សាប្រភេទទី១

# ជំពូកទី៤៖
# ពណ៌នាមុខវិជ្ជា

**១០១១០០ ការអប់រំដើម្បីការអភិវឌ្ឍប្រកបចីរភាព ៣ (៣-០-៩)**

Education for Sustainable development

មុខវិជ្ជានេះសិក្សាពីទស្សនាទាន គោលការណ៍ និងការអនុវត្តការអភិវឌ្ឍដោយចីរភាពក្នុងការរៀននិងការបង្រៀន តួនាទីនៃការអប់រំសម្រាប់ដោះស្រាយបញ្ហា ដោយផ្តោតលើសសរស្តម្ភ នៃការអភិវឌ្ឍដោយចីរភាពដូចជាបរិស្ថាន សង្គម និងសេដ្ឋកិច្ចជាដើម ព្រមទាំងការអប់រំគោលការណ៍និងយុទ្ធសាស្ត្រអប់រំ ប្រកបដោយគុណភាព ការអប់រំបរិយាបន្ន ការអប់រំ ប្រកបដោយសមធម៌ និងការសិក្សាពេញមួយជីវិត។

**១០១១០១ មូលដ្ឋានគ្រឹះការស្រាវជ្រាវអប់រំ ៣ (៣-០-៩)**

Fundamentals of Educational Research

មុខវិជ្ជានេះសិក្សាពីធម្មជាតិ និងប្រភេទ (Nature and Types) នៃការស្រាវជ្រាវអប់រំ ដំណើរការនៃការ ស្រាវជ្រាវអប់រំ ការរំលឹកទ្រឹស្តីនិងការកំណត់បញ្ហានៃការស្រាវជ្រាវអប់រំ ការបង្កើតសម្មតិកម្ម ការកំណត់ អថេរនិងដែនកំណត់នៃការស្រាវជ្រាវ លំហសំណាក (Population) និងសំណាកនៃ ការស្រាវ ជ្រាវ (Sample)។

**១០១៣១២ ការសិក្សាប្រៀបធៀបផ្នែកគ្រប់គ្រងអប់រំ ៣ (៣-០-៩)**

Comparative Study in Educational Management

ការសិក្សាប្រៀបធៀបពីគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ប្រព័ន្ធគ្រប់គ្រងអប់រំ និងការគ្រប់គ្រងគ្រឹះ ស្ថានអប់រំនានា ដូចជា នវានុវត្តន៍នៃការគ្រប់គ្រងអប់រំ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ក្នុង វិស័យអប់រំ នៅថ្នាក់ជាតិ តំបន់ និងសាកលលោក ដើម្បីឆ្លុះបញ្ចាំងពីកិច្ចដំណើរការគ្រប់គ្រងវិស័យអប់រំ និងកែលម្អ បង្កើតផែនការយុទ្ធសាស្ត្រវិស័យអប់រំ យន្តការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការអនុ វត្ត និងអភិវឌ្ឍន៍ការងារគ្រប់គ្រងអប់រំឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

**១០៣១៣ ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ៣ (៣-០-៩)**

Human Resource Management in Education

មុខវិជ្ជានេះសិក្សាពីទ្រឹស្តី ទម្រង់ យុទ្ធសាស្ត្រកំណែទម្រង់ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សក្នុងស្ថាប័ន ឬអង្គភាពអប់រំ ដោយពិនិត្យលើមុខងារសំខាន់ៗដែលត្រូវបានអនុវត្តក្នុងការងារ

អប់រំ ដូចជា៖ ការ ប្រើ ប្រាស់អភិបាលកិច្ចល្អ ការគ្រប់គ្រង និងបែងចែកធនធានមនុស្ស គំនិតច្នៃប្រឌិត គុណធម៌ និងមនសិ ការវិជ្ជាជីវៈក្នុងការតែងតាំង ការជ្រើសរើស ការបណ្តុះបណ្តាល និងការវាយតម្លៃ ។

**១០១២០០ ការវិភាគស៊ីជម្រៅលើការអប់រំ ៣ (៣-០-៩)**

Critical Analysis in Education

មុខវិជ្ជានេះសិក្សាពីទម្រង់ របៀប ដំណើរនៃការវិភាគត្រិះរិះពិចារណាស៊ីជម្រៅ ការគិតបែបគ្រប់ជ្រុង ជ្រោយ ការវិភាគបែបសំយោគ ការគិតបែបសមហេតុសមផល ការគិតជាប្រព័ន្ធ ការគិតបែបនវានុវត្ត ការ វិភាគលើទស្សនាទាននិងបញ្ហាប្រឈមក្នុងវិស័យអប់រំ ដើម្បីស្វែងរកជម្រើសនិងមធ្យោបាយថ្មីៗ សម្រាប់ កែលម្អការអប់រំឱ្យកាន់តែប្រសើរសមស្របតាមតម្រូវការនៃស្ថានភាពជាក់ស្តែងនិងការវិវឌ្ឍ របស់សង្គម នាពេលបច្ចុប្បន្ននិងអនាគត។

**១០១២៥១ វិធីសាស្ត្រការស្រាវជ្រាវអប់រំកម្រិតខ្ពស់ ៣ (៣-០-៩)**

Advanced Research Methodology in Education

មុខវិជ្ជានេះសិក្សាស៊ីជម្រៅពីការកំណត់ទម្រង់ស្រាវជ្រាវអប់រំ ការជ្រើសរើសសំណាក ការបង្កើតនិងត្រួត ពិនិត្យគុណភាពឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសស្ថិតិយកមកប្រើឲ្យស្របតាមសំនួរស្រាវជ្រាវ ការបក ស្រាយទិន្នន័យ ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ព្រមទាំងការសរសេរនិក្ខេបបទ។

**១០១៣០០ ការអភិវឌ្ឍគោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ ៣ (៣-០-៩)**

Developing Educational Policy and Strategic Management

មុខវិជ្ជានេះសិក្សាពីគោលការណ៍ ទស្សនាទាន និងទ្រឹស្តីនៃការអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រ គ្រប់គ្រងអប់រំស្របតាមបរិបទអប់រំឌីជីថលរបស់ប្រទេស តំបន់ និងសាកលលោក វិធីសាស្ត្រនាំយកគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងអប់រំទៅអនុវត្ត និងការវាយតម្លៃលទ្ធផលនៃការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ។

**១០១៣០៧ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដើម្បីការផ្លាស់ប្តូរក្នុងវិស័យអប់រំ ៣ (៣-០-៩)**

Leadership and Change Management in Education

មុខវិជ្ជានេះសិក្សាពីលក្ខណៈសម្បត្តិ គោលការណ៍ គោលនយោបាយ ទស្សនាទាន និងទ្រឹស្តីនៃការគ្រប់ គ្រង និងភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ ដូចជាភាពជាអ្នកដឹកនាំបែបយុទ្ធសាស្ត្រ (Strategic Leaders) ភាពជាអ្នកដឹកនាំដើម្បីការផ្លាស់ប្តូរជាវិជ្ជមាន កាគ្រប់គ្រងការផ្លាស់ប្តូរ

(Change Management) ការគ្រប់គ្រងទំនាស់ ការគ្រប់គ្រងហានិភ័យ ទស្សនវិស័យ គុណធម៌ចរិយាធម៌ គំនិតថ្មី ពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំលើវិស័យអប់រំ។

**១០១៣០៥ ការស្រាវជ្រាវផ្នែកគ្រប់គ្រងអប់រំដើម្បីការអភិវឌ្ឍប្រទេស ៣ (៣-០-៩)**

Research in Education Management for National Development

មុខវិជ្ជានេះសិក្សាពីមូលដ្ឋានគ្រឹះ គោលការណ៍ ទស្សនាទាន និងទ្រឹស្តីនៃការស្រាវជ្រាវការគ្រប់គ្រងអប់រំ ដោយផ្តោតសំខាន់លើវិធីសាស្ត្រស្រាវជ្រាវចម្រុះ ការអនុវត្តនិងការអភិវឌ្ឍការងារអប់រំ គោលការណ៍នៃ ការអភិវឌ្ឍប្រទេសជានិរន្តរ៍ និងប្រភពនៃបញ្ហាប្រឈមនានាដោយសំយោគលទ្ធផលស្រាវជ្រាវ ដើម្បី ដោះស្រាយបញ្ហា និងការអភិវឌ្ឍការងារអប់រំនិងប្រទេសជាតិប្រកបដោយភាពប៉ិនប្រសប់ និងច្នៃប្រឌិត ។

**១០១២៥០ ស្ថិតិអនុវត្តសម្រាប់ការស្រាវជ្រាវអប់រំ ៣ (៣-០-៩)**

Applied Statistics for Educational Research

មុខវិជ្ជានេះសិក្សាពីស្ថិតិព័ណ៌នាដូចជាអថេរ (Variables) រង្វាស់តម្លៃកណ្តាល (Cental Tendency) រង្វាស់ពង្រាយ (Dispersion) ក្រាហ្វិក និងស្ថិតិសន្និដ្ឋានដូចជា Z-TEST, T-TEST, F-TEST, ANOVA, CORRELATION និង REGRESSION ។

**១០១ ៣០១ បញ្ហានិងនិន្នការក្នុងផ្នែកគ្រប់គ្រងអប់រំ ៣ (៣-០-៩)**

Current Issues and Trends in Educational Management

មុខវិជ្ជានេះសិក្សាពី ទិដ្ឋភាពទូទៅ និងទំនោរការគ្រប់គ្រងអប់រំនាពេលបច្ចុប្បន្ន ដូចជាវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងទ្រឹស្តីជាមូលដ្ឋាននៃការគ្រប់គ្រងការងារអប់រំ ការគ្រប់ គ្រង ការ បង្រៀន និងរៀន ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងថវិកា។

**១០១៣០៨ ការគ្រប់គ្រងកម្មវិធីសិក្សា ៣ (៣-០-៩)**

Curriculum Management

មុខវិជ្ជានេះសិក្សាពីការគ្រប់គ្រងកម្មវិធីបង្រៀននិងរៀន ការគ្រប់គ្រងនិងការលើកកម្ពស់ការអនុវត្តកម្ម វិធី សិក្សារបស់បុគ្គលិកអប់រំ ការគ្រប់គ្រងលើការពង្រឹងគុណភាពកម្មវិធីសិក្សា សិក្សាពីកត្តាផ្សេងៗ ដែលពាក់ព័ន្ធ នឹងការគ្រប់គ្រងកម្មវិធីសិក្សា។

**១០១៣១០ ការគ្រប់គ្រងនវានុវត្តន៍ និងគំនិតច្នៃប្រឌិតផ្នែកអប់រំ ២ (២-០-៦)**

Management of Innovation and Creativity in Education

មុខវិជ្ជានេះសិក្សាពីការគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ ការគ្រប់គ្រងលើការងារអប់រំឌីជី ថល (Digital Education) ការគ្រប់គ្រងលើការច្នៃប្រឌិតការងារអប់រំ និងការគ្រប់គ្រងលើ បរិយាកាស ការអប់រំ ជាក់ស្តែង។

**១០១៣០២ ការគ្រប់គ្រងអប់រំដើម្បីសហគមន៍សកល ២ (២-០-៦)**

Educational Management for Global Community

មុខវិជ្ជានេះសិក្សាពីបរិបទសាកលលើការគ្រប់គ្រងការអប់រំ ព្រមទាំងនិរន្តរភាពនៃការគ្រប់គ្រងអប់រំ ការ លើកកម្ពស់ការយល់ដឹងលើការអប់រំសាកល និងការគ្រប់គ្រងការអប់រំដើម្បី បណ្ដុះបណ្ដាលធនធាន មនុស្សក្លាយជាពលរដ្ឋសាកល។

**១០១៣០៣ ការអភិវឌ្ឍបទដ្ឋាន(ស្តង់ដា)អាជីពគ្រប់គ្រងអប់រំ ២ (២-០-៦)**

Developing Professional Standards of Educational Management

មុខវិជ្ជានេះសិក្សាពីគោលការណ៍គ្រប់គ្រងកិច្ចការអប់រំ កម្រងភារកិច្ចនិងការទទួលខុសត្រូវ និងចរិត ឬឥរិយា បថគ្រប់គ្រង កត្តាដែលធ្វើឱ្យការគ្រប់គ្រងការងារអប់រំមានប្រសិទ្ធភាពខ្ពស់ និងការស្រាវជ្រាវ រៀបចំស្តង់ដា សមត្ថភាពវិជ្ជាជីវៈអ្នកគ្រប់គ្រងអប់រំស្របតាមការវិវត្តរបស់ប្រទេសក្នុងតំបន់ និង សកល លោក។

**១០១៣០៤ ការអភិវឌ្ឍការគ្រប់គ្រងទូទៅ ថវិកា និងគណនេយ្យផ្នែកអប់រំ ៣ (៣-០-៩)**

Developing General, Budgeting and Financial Management in Education

មុខវិជ្ជានេះសិក្សាពីម៉ាក្រូសេដ្ឋកិច្ច ច្បាប់ថវិកា និតិវិធីហិរញ្ញវត្ថុ និងនវានុវត្តន៍ក្នុងការគ្រប់គ្រងទូទៅ និងហិរញ្ញវត្ថុ ការវិភាគការអនុវត្តថវិកា ការគ្រប់គ្រងទូទៅ និងផលប៉ះពាល់នៅតាមអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការស្វែងរកបញ្ហាប្រឈម និងការគន្លឹះដើម្បីកសាងវិធីសាស្ត្រ ( Sophisticate Approach Based Education Budgets/ Performance-Based Budget)និងឧបករណ៍ វាយតម្លៃ សម្រាប់កែលម្អការងារគ្រប់គ្រងទូទៅ និង គ្រប់គ្រងហិរញ្ញវត្ថុក្នុងវិស័យអប់រំ។

**១០១៣១១ ក្រមសីលធម៌អ្នកដឹកនាំលើវិស័យអប់រំ ៣ (៣-០-៩)**

Ethics for Educational Leaders

មុខវិជ្ជានេះសិក្សាពីការវិភាគបែបសំយោគ គុណតម្លៃនិងសារៈសំខាន់របស់គុណធម៌ ចរិយាធម៌ នៅក្នុង ការគ្រប់ គ្រងអប់រំ ជាតុផ្សំនៃក្រមសីលធម៌សំខាន់ៗសម្រាប់អ្នកគ្រប់គ្រងអប់រំដើម្បីឲ្យក្លាយជាគំរូ ដល់សង្គម និងការ សម្រេចចិត្តរបស់អ្នកដឹកនាំដោយផ្សារភ្ជាប់ភាពជាអ្នកដឹកនាំជាមួយក្រមសីលធម៌។

**១០១៣១៤ ការគ្រប់គ្រងការអប់រំបច្ចេកទេស ៣ (៣-០-៩)**

Administration of Vocational and Technical Education

មុខវិជ្ជានេះសិក្សាពី គោលការណ៍ ទស្សនាទាន ទ្រឹស្តី បញ្ហា និងនិន្នាការនៃការគ្រប់គ្រង និងការអភិវឌ្ឍកម្មវិធីសិក្សាការអប់រំបច្ចេកទេស ព្រមទាំងសិក្សាវិភាគពីទំនាក់ទំនងរវាងការបណ្តុះបណ្តាលធនធានមនុស្សជាមួយតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម ៤.០។

**១០១៥០០ និក្ខេបបទ១ ប្រភេទ១ Dissertation 1, Type 1 ៣ ក្រេឌីត**

ជំហានដំបូងនៃការងារស្រាវជ្រាវដោយសិក្សាលើការរំលឹកទ្រឹស្តីទាក់ទងនឹងការគ្រប់គ្រងអប់រំ ការកំណត់ ប្រធានបទនៃការងារស្រាវជ្រាវ ក្របខ័ណ្ឌនៃការងារស្រាវជ្រាវ ( Conceptual Framework and Conceptual Innovation )។

**១០១៥០១ និក្ខេបបទ២ ប្រភេទ១ Dissertation 2, Type 1 ៣ ក្រេឌីត**

ការស្នើសេចក្តីព្រាងនៃគម្រោងស្រាវជ្រាវបឋមជូនគណៈកម្មការត្រួតពិនិត្យ និងកែលម្អតាមការណែនាំរបស់គណៈកម្មការ។

**១០១៥០២ និក្ខេបបទ៣ ប្រភេទ១ Dissertation 3, Type 1 ៣ ក្រេឌីត**

ការស្នើការពារគម្រោងស្រាវជ្រាវ( Submit draft of the proposal, present the research proposal to the committee members )

**១០១៥០៣ និក្ខេបបទ៤ ប្រភេទ១ Dissertation 4, Type 1 ៦ ក្រេឌីត**

ដំណើរការកសាងឧបករណ៍ប្រមូលទិន្នន័យ ការវាយតម្លៃសុពលភាពពីអ្នកជំនាញ( Validity Check ) និងការធ្វើតេស្តសាកល្បងឧបករណ៍ប្រមូលទិន្នន័យ (Reliability Check)។

**១០១៥០៤ និក្ខេបបទ៥ ប្រភេទ១ Dissertation 5, Type 1 ៩ ក្រេឌីត**

ការប្រមូលទិន្នន័យ(Data Collection) ការបញ្ចូលទិន្នន័យ(Data Entry) ការដំណើការសម្អាត ទិន្នន័យ(Data Processing and Cleaning) ការវិភាគទិន្នន័យ (Data Analysis) និងការបក ស្រាយទិន្នន័យ (Data Interpretation)

**១០១៥០៥ និក្ខេបបទ៦ ប្រភេទទី១ Dissertation 6, Type 1 ៩ ក្រេឌីត**

ការសរសេររបាយការណ៍ការស្រាវជ្រាវ( និក្ខេបបទ ) ស្នើប្រឡងការពារនិក្ខេបបទផ្ទាល់មាត់ និងបោះពុម្ព។

**១០១៥២៥ និក្ខេបបទ១ ប្រភេទទី២ Dissertation 1, Type 2 ៦ ក្រេឌីត**

ជំហានដំបូងនៃការងារស្រាវជ្រាវដោយសិក្សាលើការរំលឹកទ្រឹស្តីទាក់ទងនឹងការគ្រប់គ្រងអប់រំ ការកំណត់ប្រធានបទនៃការងារស្រាវជ្រាវ ក្របខ័ណ្ឌ នៃការងារស្រាវជ្រាវ ( Conceptual Framework and Conceptual Innovation )។ ស្នើសេចក្តីព្រាងនៃគម្រោងស្រាវជ្រាវបឋម ជូនគណៈកម្មការត្រួតពិនិត្យ និងកែលម្អតាមការណែនាំរបស់គណៈកម្មការ និងស្នើការពារគម្រោងស្រាវជ្រាវ។

**១០១៥២៦ និក្ខេបបទ២ ប្រភេទទី២ Dissertation 2, Type 2 ៦ ក្រេឌីត**

ការប្រមូលទិន្នន័យ( Data Collection ) ការបញ្ចូលទិន្នន័យ( Data Entry ) ការដំណើការសម្អាតទិន្នន័យ( Data Processing and Cleaning ) ការវិភាគទិន្នន័យ ( Data Analysis ) និងការបក ស្រាយទិន្នន័យ ( Data Interpretation )

**១០១៥២៧ និក្ខេបបទ៣ ប្រភេទទី២ Dissertation 3, Type 3 ៦ ក្រេឌីត**

ការសរសេររបាយការណ៍ការស្រាវជ្រាវ( និក្ខេបបទ ) ស្នើប្រឡងការពារនិក្ខេបបទផ្ទាល់មាត់ និងបោះពុម្ព។

**២៨. ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬអន្តរជាតិ ៦ ក្រេឌីត**

ចុះផ្សាយអត្ថបទស្រាវជ្រាវចំនួន២អត្ថបទក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រកម្រិតជាតិ និងអន្តរជាតិដែលមានបណ្ណាធិការ និងអ្នកត្រួតពិនិត្យឯករាជ្យថ្នាក់ជាតិ ឬអន្តរជាតិ។

**២៩. ការធ្វើបទបង្ហាញអត្ថបទស្រាវជ្រាវក្នុងវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ ៣ ក្រេឌីត**

ធ្វើបទបង្ហាញអត្ថបទស្រាវជ្រាវដែលត្រូវចុះផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ នៅក្នុងវេទិកាវិទ្យាសាស្ត្រជាតិ និង អន្តរជាតិដែលមានលក្ខណៈ Conference Proceedings ចំនួនយ៉ាងតិច ០១ដង។

**៣០. ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ៣ ក្រេឌីត**

ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន គឺជាការឡើងធ្វើបទបង្ហាញនូវលទ្ធផល និងចំណេះដឹងដែលបានមកពីការស្រាវ ជ្រាវរបស់ខ្លួនដែលត្រូវធ្វើចំនួន២ដង ដើម្បីស្វែងរកភាពចន្លោះប្រហោង និងចំណុចខ្សោយរបស់និក្ខេបបទ តាមរយៈការរិះគន់ សំណួរ និងការបកស្រាយ និងអនុសាសន៍ពីក្រុមអ្នកជំនាញពាក់ព័ន្ធ សំដៅធ្វើឱ្យនិក្ខេបបទកាន់ តែមានភាពសុក្រិត និងឆ្ពោះទៅរកការបញ្ចប់ដោយជោគជ័យ។ សិក្ខាសាលានីមួយៗ ត្រូវរៀបចំដោយ គណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា។

# ឯកសារយោង៖

1- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ខែកញ្ញា ឆ្នាំ ២០១៨។
2- ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ខែមីនា ឆ្នាំ២០១៤។
3- សេចក្តីណែនាំលម្អិតស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ឆ្នាំ២០១២។
4- ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនសាកលវិទ្យាល័យជូឡាឡុងកន ឆ្នាំ២០១៨។

## ឧបសម្ព័ន្ធ១៖ អត្ថន័យលេខកូដមុខវិជ្ជា




| ល.រ | ឈ្មោះ ដេប៉ាតឺម៉ង់ និងជំនាញ | លេខកូដ៣ខ្ទង់មុខ |
|---|---|---|
| ១ | ដេប៉ាតឺម៉ង់អប់រំ | ១០០ XXX |
| ២ | ជំនាញគ្រប់គ្រងអប់រំ | ១០១ XXX |
| ៣ | ជំនាញកម្មវិធីសិក្សា | ១០២ XXX |

| ល.រ | ឈ្មោះក្រុមមុខវិជ្ជា | លេខកូដ ៣ ខ្ទង់ក្រោយ |
|---|---|---|
| ១ | មុខវិជ្ជាវិជ្ជាបំពេញបន្ថែម | XXX(១០០→១៩៩) |
| ២ | មុខវិជ្ជាវិជ្ជាកម្រិតបណ្ឌិត | XXX(២០០→២៩៩) |
| | - មុខវិជ្ជាវិជ្ជារួមនៃឯកទេស | XXX(២០០→២៤៩) |
| | - មុខវិជ្ជាវិជ្ជាស្នូលនៃឯកទេស | XXX(២៥០→២៩៩) |
| ៣ | មុខវិជ្ជាតម្រង់ទិស និងការប្រឡងទូទៅ | XXX(៣០០→៤៩៩) |
| ៤ | និក្ខេបបទ | XXX(៥០០→៥៩៩) |
| | - និក្ខេបបទប្រភេទ១ | XXX(៥០០→៥២៤) |
| | - និក្ខេបបទប្រភេទ២ | XXX(៥២៥→៥៩៩) |
| ៥ | ការប្រឡងវាស់ស្ទង់គុណសម្បត្តិ | XXX ៥៥០ |